គណៈកម្មាធិការដើម្បីការបោះឆ្នោតដោយសេរីនិងយុត្តិធម៌នៅកម្ពុជា

Committee for Free and Fair Elections in Cambodia

ខុមហ្វ្រែល COMFREL


ថ្ងៃទី ២៣ ខែមីនា ឆ្នាំ២០១២

# <u>សេចក្តីប្រកាសព័ត៌មាន</u>

# <u>ស្តីពី</u>

## <u>លទ្ធផលសិក្ខាសាលាសម្លេងម្ចាស់ឆ្នោតឃុំបាក់អន្លូង ស្រុកត្រពាំងប្រាសាទ ខេត្តឧត្តរមានជ័យ</u>

ដោយមានការគាំទ្រពីគណៈកម្មាធិការខុមហ្វ្រែល សហការជាមួយនឹង **សមាគមអាដហុក** បានរៀបចំសិក្ខាសាលាសម្លេងម្ចាស់ឆ្នោតមួយស្តីពី**ការកំណត់តម្រូវការជាអាទិភាពក្នុងឃុំ សង្កាត់ដាច់ស្រយាល** ដែលធ្វើឡើងនៅឃុំ**បាក់អន្លូង ស្រុកត្រពាំងប្រាសាទ ខេត្តឧត្តរមានជ័យ** កាលពីថ្ងៃទី១៩ ខែមីនា ឆ្នាំ២០១២។ មានអ្នកមានសិទ្ធិបោះឆ្នោតប្រមាណ**៥១**នាក់(**៤៥%**ជាស្ត្រី) មកពីគ្រប់ភូមិក្នុងឃុំ ដែលរួមមានតំណាងសហគមន៍ តំណាងគណបក្សនយោបាយប្រចាំឃុំ សមាជិកក្រុមប្រឹក្សាឃុំ អាជ្ញាធរភូមិ អង្គការមូលដ្ឋាន និងប្រជាពលរដ្ឋនៅក្នុងឃុំបានចូលរួមពិភាក្សានៅក្នុងសិក្ខាសាលានេះ។

ប្រជាពលរដ្ឋដែលចូលរួមសិក្ខាសាលាស្ទើរតែ ១០០% បានបោះឆ្នោតគាំទ្រតម្រូវការជាអាទិភាពទាំង៥នៅក្នុងឃុំ ដែលស្នើឱ្យក្រុមប្រឹក្សាឃុំបច្ចុប្បន្នយកចិត្តទុកដាក់ដោះស្រាយ និង/ឬ គណបក្សនយោបាយទទួលយកដើម្បីដាក់បញ្ចូលទៅក្នុង កម្មវិធីនយោបាយរបស់ខ្លួនក្នុងការបោះឆ្នោតឃុំ-សង្កាត់ខាងមុខ។

| **តម្រូវការជាអាទិភាពទាំង៥ ក្នុងឃុំបាក់អន្លង់ ស្រុកត្រពាំងប្រាសាទ ខេត្តឧត្តរមានជ័យ** |
|---|
| **១. ការសាងសង់ផ្លូវលំ ស្ពាន និងដាក់លូ**<br>• ស្នើសុំផ្លូវលំថ្មី**៥ខ្សែ**ក្រាលគ្រួសក្រហម ដែលផ្លូវនីមួយៗមានប្រវែង៥គីឡូម៉ែត្រ ទទឹង៥ម៉ែត្រ បាត១២ម៉ែត្រ និងកម្ពស់០,៥ម៉ែត្រ ដូចៗគ្នា៖<br>- **ខ្សែទី១** ពីដើមភូមិសុខសិរី ទៅដល់ចុងភូមិសុខសិរី និងធ្វើស្ពានថ្មបេតុង១កន្លែង មានប្រវែង៣០ម៉ែត្រ កម្ពស់៥ម៉ែត្រ ទទឹង៦ម៉ែត្រ បាត៨ម៉ែត្រ នៅចំណុចកណ្តាលភូមិ និងដាក់លូ១កន្លែងនៅចំណុចដើមភូមិ មានមុខកាត់១ម៉ែត្រ បណ្តោយ១ម៉ែត្រ ចំនួន៦កង់។<br>- **ខ្សែទី២** ពីដើមភូមិមានជ័យ ទៅដល់ចុងភូមិមានជ័យ និងធ្វើ**ស្ពាន**ថ្មបេតុង១កន្លែង មានប្រវែង៣០ម៉ែត្រ កម្ពស់៥ម៉ែត្រ ទទឹង៦ម៉ែត្រ បាត៨ម៉ែត្រ នៅចំណុចអូរបាក់អន្លូង និង**ដាក់លូ**១កន្លែង នៅចំណុចកណ្តាលភូមិ មានមុខកាត់១ម៉ែត្រ បណ្តោយ១ម៉ែត្រ ចំនួន៦កង់។<br>- **ខ្សែទី៣** ពីដើមភូមិសំបូរ ទៅដល់ចុងភូមិសំបូរ និងធ្វើ**ស្ពានថ្ម**បេតុង១កន្លែង មានប្រវែង៣០ម៉ែត្រ កម្ពស់ ០,៥ម៉ែត្រ ទទឹង៦ម៉ែត្រ បាត៨ម៉ែត្រ នៅចំណុចអូរជី**ផុន ចុន** និង**ដាក់លូ**១កន្លែង នៅចំណុចចុងភូមិ មានមុខកាត់១ម៉ែត្រ បណ្តោយ១ម៉ែត្រ ចំនួន៦កង់។ |


Vision : A democratic society that democratization in particular democratic elections are promoted and qualified to bring benefits to people.

ទស្សនៈវិស័យ ៖ ដើម្បីឱ្យការបោះឆ្នោតមានគុណភាព ដើម្បីប្រយោជន៍ប្រជាពលរដ្ឋ



<u>ទីស្នាក់ការកណ្តាល</u> ៖ ផ្ទះលេខ ១៣៨ ផ្លូវ ១២២ សង្កាត់ ទឹកល្អក់ ១ ខណ្ឌ ទួលគោក រាជធានីភ្នំពេញ ព្រះរាជាណាចក្រកម្ពុជា

<u>Central Office</u> : #138, Street. 122, TeukLaak I, TuolKork, Phnom Penh, CAMBODIA.

P.O. Box1145, Phone : (855) 23 884 150 **Fax**: (855) 23 885 745 **E-mail** : comfrel@online.com.kh **Website**: www.comfrel.org

- **ខ្សែទី៤** ពីដើមភូមិទូលប្រសើរ ទៅដល់ចុងភូមិទូលប្រសើរ និងធ្វើ**ស្ពានថ្ម**បេតុង១កន្លែង ប្រវែង៣០ម៉ែត្រ កម្ពស់៥ម៉ែត្រ ទទឹង៦ម៉ែត្រ បាត៨ម៉ែត្រ នៅចំណុចចុងភូមិ និង**ដាក់លូ**១កន្លែង នៅចំណុចជិតកន្លែងធ្វើស្ពានចុងភូមិ មានមុខកាត់១ម៉ែត្រ បណ្តោយ១ម៉ែត្រ ចំនួន៦កង់។
- **ខ្សែទី៥** ពីដើមភូមិស្រែល្អ ទៅដល់ចុងភូមិស្រែល្អ និងធ្វើ**ស្ពានថ្ម**បេតុង១កន្លែង ប្រវែង៣០ម៉ែត្រ កម្ពស់៥ម៉ែត្រ ទទឹង៦ម៉ែត្រ បាត៨ម៉ែត្រ នៅចំណុចអូរល្បៀង និង**ដាក់លូ**១កន្លែង នៅចំណុចចុងដីតាពិន មានមុខកាត់១ម៉ែត្រ បណ្តោយ១ម៉ែត្រ ចំនួន៦កង់។ សំណើរខាងលើនេះសូមចាប់ផ្តើមពីឆ្នាំ២០១២ និងបញ្ចប់នៅឆ្នាំ២០១៤។

### ២. ការស្នើសុំសាងសង់បង្គន់ ប៉ុស្តិ៍សុខភាព

- ស្នើសុំបង្គន់អនាម័យសម្រាប់ទូទាំងឃុំបាក់អន្លូង សរុបចំនួន២៥២បង្គន់ និងមុងជ្រលក់ថ្នាំចំនួន២៥០០មុងទូទាំងឃុំ។ សូមចាប់ផ្តើមពីឆ្នាំ២០១២ និងបញ្ចប់នៅឆ្នាំ២០១៤។
- ស្នើសុំឲ្យមានមធ្យោបាយដឹកជញ្ជូនអ្នកជម្ងឺ អ្នកសំរាលកូនទៅមន្ទីរពេទ្យបង្អែកឲ្យបានទាន់ពេលវេលា និងសុំថ្នាំលាបរបួសសង្គ្រោះបន្ទាន់ឲ្យបានគ្រប់ភូមិ និងស្នើសុំធុងជ័រដាក់ទឹកចំនួន១៥០ធុង សម្រាប់ភូមិទាំង៥ នៅក្នុងឃុំទាំងមូល។ សូមចាប់ផ្តើមពីឆ្នាំ២០១២ និងបញ្ចប់នៅឆ្នាំ២០១៤។
- ស្នើសុំអណ្តូងទឹកស្អាតសម្រាប់ភូមិទាំង៥ក្នុងឃុំ សរុបចំនួន២៥អណ្តូង។ សូមចាប់ពីឆ្នាំ២០១២ និងបញ្ចប់ឆ្នាំ២០១៤។

### ៣. ការជួសជុលទំនប់

- ស្នើសុំជួសជុលទំនប់ថ្មី១កន្លែង មានខ្នងលើ៧ម៉ែត្រ បាត១៥ម៉ែត្រ បណ្តោយ៣០០ម៉ែត្រ កម្ពស់២ម៉ែត្រ នៅចំណុចអូរទឹកថ្លា ក្នុងភូមិស្រែល្អ។ សូមចាប់ផ្តើមពីឆ្នាំ២០១២ និងបញ្ចប់ឆ្នាំ២០១៤។
- ស្នើសុំជួសជុលទំនប់បង្ហៀរទឹកចាស់៣កន្លែង **ទី១**នៅភូមិសុខសិរី មានបណ្តោយ៣០ម៉ែត្រ ទទឹង៦ម៉ែត្រ **ទី២**នៅភូមិស្រែល្អ មានបណ្តោយ៩០ម៉ែត្រ ទទឹង៨ម៉ែត្រ **ទី៣**នៅភូមិទទូលប្រសើរ មានបណ្តោយ៣០ម៉ែត្រ ទទឹង១៥ម៉ែត្រ។ សូមចាប់ផ្តើមពីឆ្នាំ២០១២ និងបញ្ចប់ឆ្នាំ២០១៤។

### ៤. ការស្នើសុំជួយដោះស្រាយបញ្ហាដីធ្លី និងបើកវគ្គបណ្តុះបណ្តាល

- ស្នើសុំជួយដោះស្រាយដីចំនួន៣០ហិចតាដែលទាហានរំលោភយកធ្វើទីបញ្ជាការ លើដីប្រជាពលរដ្ឋចំនួន១៧គ្រួសារ នៅភូមិស្រែល្អ។ សូមចាប់ផ្តើមពីឆ្នាំ២០១២ និងបញ្ចប់ឆ្នាំ២០១៤។
- ស្នើសុំវគ្គបណ្តុះបណ្តាលបច្ចេកទេសរបៀបធ្វើជីធម្មជាតិ ជីអ៊ីអឹម ឲ្យបាន៥វគ្គ ក្នុង១ឆ្នាំ។ សូមចាប់ផ្តើមពីឆ្នាំ២០១២ និងបញ្ចប់នៅឆ្នាំ២០១៤។
- ស្នើសុំជួយផ្តល់ពូជស្រូវល្អៗ ចំនួន៣០គីឡូក្រាមក្នុង១គ្រួសារ និងផ្តល់ពូជជ្រូកល្អៗចំនួន៣០ក្បាលក្នុង១ឃុំ។ សូមចាប់ផ្តើមពីឆ្នាំ២០១២ និងបញ្ចប់ឆ្នាំ២០១៤។

**៥. ការស្នើសុំសាងសង់សាលា គ្រូបង្រៀន និងបើកវគ្គបណ្តុះបណ្តាល**

- ស្នើសុំផ្សព្វផ្សាយអប់រំស្តីអំពីច្បាប់ចរាចរណ៍ និងច្បាប់ប្រើប្រាស់គ្រឿងញៀន ឲ្យបាន៣វគ្គ ក្នុង១ឆ្នាំ។ សូមចាប់ផ្តើមពីឆ្នាំ២០១២ ដល់ឆ្នាំ២០១៣។
- ស្នើសុំបើកវគ្គបណ្តុះបណ្តាលអំពីច្បាប់ហិង្សាក្នុងគ្រួសារ ការជួញដូរស្ត្រី និងកុមារ ការជួញដូរកំលាំងពលកម្ម ចំនួន៥វគ្គ ដោយក្នុង១វគ្គ សម្រាប់១ភូមិ។ សូមចាប់ផ្តើមពីឆ្នាំ២០១២ បញ្ចប់នៅឆ្នាំ២០១៥។
- ស្នើសុំជួយផ្តល់អាហារូបករណ៍ដល់សិស្សក្រីក្រ។ សូមចាប់ផ្តើមពីឆ្នាំ២០១២ ដល់ឆ្នាំ២០១៥។

មុនពេលបញ្ចប់សិក្ខាសាលាមានកម្មវិធីប្រគល់របាយការណ៍ពីតម្រូវការជាអាទិភាពដល់អ្នកដឹកនាំគណបក្សនយោបាយប្រចាំឃុំ និងក្រុមប្រឹក្សាឃុំ។

លោក **ភិន យ៉ុន** ជាតំណាងគណៈបក្សប្រជាជនកម្ពុជា និងជាប្រធានក្រុមប្រឹក្សាឃុំ បានមានប្រសាសន៍ថា «*ថ្ងៃនេះឃើញថាមានការពិភាក្សាគ្នាយ៉ាងផុសផុល ដើម្បីរកតម្រូវការអាទិភាពក្នុងភូមិនីមួយៗ ដូចដែលបានលើកឡើងនេះ ដើម្បីការអភិវឌ្ឍរបស់ឃុំយើង។ ចំនែកការធ្វើផែនការ យើងត្រូវចូលរួមទាំងអស់គ្នាដើម្បីអនុវត្តឲ្យស្របទៅតាមគោលការណ៍របស់យើងចង់បាន។ ហើយខ្ញុំសូមអរគុណដល់អង្គការខុមហ្វ្រែល ដែលបានចូលរួមបើកវគ្គសិក្ខាសាលាក្នុងថ្ងៃនេះ ធ្វើឲ្យឃុំបាក់អន្លូងមានការយល់ដឹង និងផ្តល់ជាមតិដើម្បីធ្វើផែនការបន្តទៅមុខទៀត ចាប់ពីឆ្នាំ២០១២ ដល់ ឆ្នាំ២០១៤*»។

លោក **ម៉ែន ម៉ន** តំណាងគណៈបក្សសមរង្ស៊ី និងជាជំទប់ទី២ បានមានប្រសាសន៍ថា «លោកចាប់អារម្មណ៍ចំពោះបញ្ហា២ គឺទី១បញ្ហាតម្រូវការផ្លូវលំ អណ្តូងទឹក ទី២បង្គន់អនាម័យ បញ្ហាសេវាសុខភាព ខ្ញុំនិងខិតខំជួយជម្រុញផ្នែកអង្គការ ស្ថាប័ន ក្រសួងមានសមត្ថកិច្ច ដើម្បីជួយខ្នះខ្នែង និងយកចិត្តទុកដាក់ជួយដោះស្រាយបញ្ហារឿងដីធ្លី និងបញ្ហាផ្សេងៗទៀត ជូនតាមតម្រូវការរបស់បងប្អូនប្រជាពលរដ្ឋ ដែលពាក់ព័ន្ធក្នុងសង្គមយើងទាំងមូល»។

**សិក្ខាសាលានេះមានគោលបំណងឱ្យម្ចាស់ឆ្នោតនៅតំបន់ដាច់ស្រយាលទទួលបាននូវ៖**

១. ការយល់ដឹងអំពីសិទ្ធិតួនាទី និងកាតព្វកិច្ចរបស់ម្ចាស់ឆ្នោតក្នុងការស្វែងយល់ពីតម្រូវការជាអាទិភាពក្នុងការអភិវឌ្ឍន៍នូវមូលដ្ឋាន។

២. ផ្តល់ឱកាសឱ្យម្ចាស់ឆ្នោតចូលរួម ជជែកពិភាក្សា ដើម្បីកំណត់តម្រូវការអាទិភាពក្នុងឃុំសង្កាត់របស់ខ្លួន។

៣. តម្រូវការជាអាទិភាពក្នុងឃុំ សង្កាត់ ដាច់ស្រយាលនឹងត្រូវបានចងក្រងជារបាយការណ៍ដែលអាចឱ្យសិក្ខាកាមងាយចងចាំដើម្បីចូលរួមតាមដានជម្រុញការអនុវត្តន៍របស់ក្រុមប្រឹក្សាឃុំសង្កាត់ និងការដាក់បញ្ចូលតម្រូវការក្នុងកម្មវិធីនយោបាយរបស់គណបក្សសម្រាប់ការបោះឆ្នោតឃុំសង្កាត់ឆ្នាំ២០១២។

សិក្ខាសាលានេះក៏បានទទួលការឧបត្ថម្ភមូលនិធិពីសហភាពអឺរ៉ុប (EU), OXFAM NOVIB, NPA និង Forum Syd


[1]**សម្រាប់ព័ត៌មានបន្ថែមសូមទំនាក់ទំនង៖**

១-លោក **ម្លូច ឿត** (មន្ត្រីផ្នែកបណ្ដាញ និងវេទិកា)

ទូរស័ព្ទលេខ ៖ **០១២ ៩៧១ ៣២៦**

២-អ្នកស្រី **ហោខ សុគន្ធា** (ជំនួយការផ្នែកបណ្ដាញ និងវេទិកា)

ទូរស័ព្ទលេខ ៖ **០១៧ ៥៨៣ ៨៦៩**


<u>**បេសកម្ម**</u> ៖ បេសកកម្មរបស់ខុមហ្វ្រែល គឺជួយបង្កើតបរិយាកាសគួរជាទីពេញចិត្ត និងមានពត៌មានគ្រប់គ្រាន់ ទី១/**ដើម្បីឱ្យមានដំណើរការបោះឆ្នោតដោយសេរី និងយុត្តិធម៌**តាមរយៈការបញ្ចុះបញ្ចូល តស៊ូមតិ ដើម្បីទទួលបាននូវក្របខ័ណច្បាប់សមរម្យ, ការអប់រំដើម្បីផ្ដល់ពត៌មានដល់អ្នកបោះឆ្នោត អំពីសិទ្ធិ និងសកម្មភាពចូលរួមសង្កេតការណ៍របស់ពួកគេ ដែលអាចរារាំងនូវភាពមិនប្រក្រតី ព្រមទាំងផ្ដល់នូវរបាយការណ៍អង្កេតយ៉ាងទូលំទូលាយ និងឆាប់រហ័ស ដើម្បីអាចឲ្យមានការវាយតម្លៃលើដំណើរការ បោះឆ្នោតមួយដែលមិនលំអៀង និងមិនប្រកាន់បក្សពួក ទី២/ **ដើម្បីឱ្យមានអត្ថន័យនៃដំណាក់កាលក្រោយពេលបោះឆ្នោត** តាមរយៈការអប់រំ និងវេទិកាសាធារណៈក្នុងគោលបំណងជំរុញលើកទឹកចិត្តប្រជាពលរដ្ឋឱ្យចូលរួមក្នុងកិច្ចការនយោបាយ និងការធ្វើសេចក្ដីសំរេចនានា ការតស៊ូមតិ/បញ្ចុះបញ្ចូលដើម្បីឱ្យមានការកែទម្រង់ ដំណើរការបោះឆ្នោតដែលបង្កើននូវគណនេយ្យភាព (ការទទួលខុសត្រូវ) របស់មន្ត្រីជាប់ឆ្នោត ព្រមទាំងផ្ដល់នូវរបាយការណ៍អង្កេតយ៉ាងទូលំទូលាយ និងឆាប់រហ័ស ដើម្បីអាចឱ្យមានការវាយតម្លៃមួយដែលមិនលំអៀង និងប្រកាន់បក្សពួកទៅលើការបំពេញកម្មវិធីនយោបាយ និងដំណើរការអនុវត្តន៍ការងាររបស់មន្ត្រីជាប់ឆ្នោត។

---

[1] No 095